

# ម៉ារី អាឡេចស្សង់ឌ្រីនម៉ារតាំង
# Marie Alexandrine MARTIIN
(1932-2013)

*ដោយ*

*បណ្ឌិតសភាចារ្យ* **ឃីងហុកឌី**

*កើតនាឆ្នាំ១៩៣២[1] ហើយអនិច្ចកម្មនៅឆ្នាំ២០១៣ដោយរោគាពាធ។* ***ម៉ារីអាឡេចស្សង់ឌ្រីនម៉ារតាំង*** *បានរស់នៅជាច្រើនឆ្នាំនៅប្រទេសកម្ពុជាហើយ បានធ្វើបេសកកម្មស្រាវជ្រាវនៅប្រទេសថៃជាច្រើនលើកដើម្បីបន្តការស្រាវជ្រាវ នៅតំបន់ប្រទល់ដែនខ្មែរ ថៃ។*

## តំណែង៖

*បានទទួលតំណែងនិងតួនាទីដំបូងគឺ:*

- *ជាអ្នកទទួលបន្ទុកស្រាវជ្រាវនៅមជ្ឈមណ្ឌលស្រាវជ្រាវជាតិវិទ្យាសាស្ត្រក្រុងប៉ារីសរវាងឆ្នាំ១៩៦៥* (chargé de recherche au CNRS)។

[1] Née le 11-09- 1932 (cf.annuaire des chercheurs au 30 juin 1986, CNRS, p.57).

-បន្ទាប់មកបានទទួលតំណែងជាគរុការស្រាវជ្រាវនៅមជ្ឈមណ្ឌលស្រាវជ្រាវជាតិវិទ្យាសាស្ត្រក្រុងប៉ារីសរវាងឆ្នាំ១៩៨២ (Maître de recherche au CNRS។
-នៅទីបបញ្ចប់បានទទួលតួនាទីជានាយកការជ្រាវនៅមជ្ឈមណ្ឌលស្រាវជ្រាវជាតិវិទ្យាសាស្ត្រក្រុងប៉ារីសរវាងឆ្នាំ១៩៨៥(Directeur de recherche au CNRS។

## ការសិក្សា៖

- សញ្ញាប័ត្រ សាលាជាតិជីវភាសាបូព៌ា (ENLOV) (ភាសាខ្មែរ, ១៩៦៧)[2]
-សិក្សាវប្បធម៌ឥណ្ឌាបុរាណហើយបានទទួលសញ្ញាប័ត្រភាសាសំស្រ្កឹត ឆ្នាំ ១៩៧៤។
- បរិញ្ញាប័ត្រ និង សញ្ញាប័ត្របឋណ្ឌិតតតិយភូមិផ្នែករុក្ខជាតិសាស្ត្រនៅសាកលវិទ្យាល័យប៉ារីស ស្ហ៊របោនក្នុងមហាវិទ្យាល័យវិទ្យាសាស្ត្រ នាឆ្នាំ១៩៦៨។
-បរិញ្ញាប័ត្រអក្សរសាស្ត្រនិងសញ្ញាប័ត្របណ្ឌិតរដ្ឋអក្សរសាស្ត្រនិងមនុស្សសាស្ត្រ (ឯកទេសជ្រើសរើស៖ ជាតិពិន្ទុវិទ្យា)[3].

## បេសកកម្មស្រាវជ្រាវ៖

- នៅកម្ពុជានាឆ្នាំ១៩៦៥ដល់១៩៦៦ ហើយពីឆ្នាំ១៩៦៦ដល់១៩៧២, - នៅប្រទេសថៃពីឆ្នាំ១៩៧៨ហើយពីឆ្នាំ១៩៧៩ តទៅ...

## ការបោះពុម្ពផ្សាយ៖

[2] Cf. Langues'O. Deux siècles de l'histoire de l'Ecole des langues orientales, Paris, Ed. Hervas, 1995, « Liste des diplômés», p. 408.
[3] Voir Georges Condominas : « L'ethnographie du Cambodge. A propos de l'article de J. Népote : « Pour une reconsidération de la stratégie des études orientales sur le domaine cambodgien », janv-dec. 2000, Traversées, Contribution navale, expression symboliques, Asie-Pacifique, E. de la Maison des Sciences de l'Homme, p. 533-535

## I - សៀវភៅ

1- *Introduction à l'ethnobotanique du Cambodge*. Paris : CNRS/CEDRASEMI, 1971. 257 p. + XX planches.

2- *Le mal cambodgien. Histoire d'une société traditionnelle face à ses leaders politiques 1946-87*. Paris : Hachette (Histoire des gens), 1989. 304 p. [Traduit en anglais : *Cambodia, a shattered society*. The University of California Presse, 1994, 398 p].

3- *Les Khmers Daeum, "Khmers de l'Origine". Société montagnarde et exploitation de la forêt. De l'écologie à l'histoire*. Paris, PEFEO monographies n°183, 1997. 514 p.

4- En collaboration avec Pauline DY PHON, *Guide botanique de la ville de Phnom Penh,* Phnom Penh, Annales de la Faculté de Sciences, 1972, 79 p., plan, photos.

## II - វិភាគទានក្នុងសៀវភៅរួម (ស្រង់ចេញពីស៊ីត ៖ aefek)

1- "La fête du cul chnam thmi dans les villages cambodgiens de la province de Chantaburi (Thaïlande)", *Numéro spécial du Musée National de Bangkok,* automne 1974.

2- "Ethnobotanical aspects of Cannabis in South-East Asia", *Proc. of International Congress of Anthropological and Ethnological Sciences.* Paris/La Haye, vol. : Cannabis and Culture, 1975 : 63-75.

3- "Les voyelles du cambodgien parlé dans la province de Chau Doc (Sud-Viêt Nam), in Therapan L. Thongkim & al. (ed.) : *Studies in Tai and Mon-Khmer Phonetics and Phnonology,* Bangkok, 1979 : 131-141.

4- "Les réfugiés cambodgiens. Raisons de leur exil ; tragédies et aspirations actuelles", in Georges Condominas et Richard Pottier (eds.) : *Les réfugiés originaires de l'Asie du Sud-Est et leurs motivations de départ*. Paris : E.H.E.S.S., 1981. T.1, : 188-253.

5- "Le krâma, vêtement traditionnel cambodgien", in *De la voûte céleste au terroir, du jardin au foyer*. Paris, EHESS, 1987 : 537-45.

6- "Les Khmers de Thaïlande, de l'isolement à l'assimilation", in *Aspects du monde tropical et asiatique. Hommage à Jean Delvert.* Paris : Université de Paris Sorbonne, 1991 : 133-145. Photos + planches.

7- "Histoire et peuplement du massif des Cardamomes sous la monarchie khmère", *Disciplines croisées. Hommage à Bernard Philippe Groslier*, Paris, EHESS, 1992 : 219-254.

8- "La taxinomie végétale des Khmers", pp. 27-45 in F. Bizot (éd.) : *Recherches nouvelles sur le Cambodge*. Paris, EFEO (Etudes thématiques 1), XXIII, 1994 : 27-45.

9- Madelaine GITEAU (en collaboration avec), "Saveurs et cuisine à travers les ages au Cambodge", in F.Blanchon (éd.) : *Asie. Savourer-Goûter*, Paris, Presses de l'Université de Paris-Sorbonne, 1995: 205-235.

10- « L[1]esclavage au Cambodge aux temps anciens d[1]après les sources épigraphiques et bibliographiques », in : *Formes extrêmes de dépendance, Contributions à l[1]étude de l[1]esclavage en Asie du Sud-Est, Sous la direction de Georges Condominas*, « Civilisations et sociétés », Éditions de l[1]École des Hautes Études en Sciences Sociales, Paris : 287-314.

11- " De la consommation accrue d'euphorisants au Cambodge " in : *Opiums. Les plantes du plaisir et de la convivialité en Asie,* sous la direction d'Annie Hubert et Philippe Le Failler, L'Harmattan, coll. "Recherches asiatiques", Paris, 2000 : 239-255.

12- "Les Khmers et la pluie", in *Entre ciel et terre : l'homme et le climat*. (sous presse)

13- "L'implantation du bouddhisme dans le massif des Cardamomes", in Hommage à Jean Boisselier, *Thaïlande*, Université de Silapakorn. (sous presse)

14- "La place des oiseaux dans les classifications animales khmères", in L*es Oiseaux en Asie du Sud-Est.* (à paraître)

## III- *អត្ថបទសិក្សា*

ASEMI : Asie du Sud-Est et du Monde Insulindien (Paris)
BCEGT : Bulletin du Centre d'Etudes de Géographie Tropicale (Bordeaux)
CASE : Cahiers de l'Asie du Sud-Est (Paris)
EA : Etudes Rurales (Paris)
GBS : Gardens Bulletin Singapore (Singapour)
IR : Indochina report (Singapour)
JATBA : Journal d'Agriculture Tropicale et de Botanique Appliquée (Paris)
PI : Politique Internationale (Paris)
SEA : Sud-Est Asie (Paris)
SK : Seksa Khmer (Paris)

1- "Notes sur quelques végétaux utilisés au Cambodge", *JATBA*, XVI (2-5), Fév.-Mai 1969 : 112-157.

2- MATRAS-TROUBETZKOY (en collabaration avec) : "Contribution à l'ethnobotanique des Brou (Cambodge, province Ratanakiri)", *JATBA*, XIX (1-5) : 1-92.; phot.

3-"Notes on the vegetation of the Cardamom mountains, Cambodia", *GBS*, XXVI (2); 1973 : 213-22.

4- "Essai d'ethnophytogéographie khmère", *JATBA*, XXI (7-8-9), 1974 : 219-238.

5- "Les Pear, agriculteurs-cueilleurs du Massif des Cardamomes (Cambodge)", *ER*, 53-56, 1974 : 439-447.

6- "Esquisse phonologique du Sâmree", Etudes de linguistique austroasiatique 1, *ASEMI*, V(1). 1974 : 97-105

7- "Le dialecte cambodgien parlé à Ta Tey (massif des Cardamomes)", Etudes de linguistiques austro-asiatique II, *ASEMI*, VII (1), 1976 : 71-79.

8- "Notes et actualités. Les rites de cueillettes au Cambodge", JATBA, XXIII (7-12), 1976 : 206-220.

9- "L'ethnographie de l'époque angkorienne. Remarques sur Angkor : un peuple, un art de Madeleine GITEAU", *ASEMI* VIII (1), 1977 : 103-111.

10- "Les végétaux dans l'alimentation et la médecine, dans le Cambodge d'après 1975", *ASEMI,* IX (1-2), 1978 : 209-218.

11- "Les plantes utilisées dans les camps de réfugiés cambodgiens de Thaïlande", *ASEMI,* IX (1-2), 1978 : 219-230.

12- "La cardamome en milieu cambodgiens (Cambodge et Thaïlande)", Les cultures commerciales; plantations industrielles et production paysannes (Côte d'Ivoire, Libéria, Cambodge, Indonésie), *BCEGT,* n°38. Bordeaux, 1979 : 135-157.

13- "Les écoles techniques de Phnom-Penh : la dramatique épopée du Massif des Cardamomes. Janvier-juin 1979, in " Cheminements, Ecrits offerts à Georges Condominas", *ASEMI,* XI (1-4), 1980 : 113-127. [+ Additif *ASEMI,* XII (1-2), 1981: 125]

14- "La riziculture et la maîtrise de l'eau dans le Kampuchéa Démocratique", *ER* 83, 1981 : 7-44.

15- POU Saveros (en collaboration avec) : "Les noms de plantes dans l'épigraphie vieux-khmère", in "Etudes de linguistique austroasiatique", fasc. 3, *ASEMI,* XII (1-2), 1981 : 3-73.

16- "Le gouvernement de coalition du Kampuchea démocratique : historique, bilan et perspectives", *ASEMI,* XIII (1-4), 1982 : 443-478.

17- "Eléments de médecine traditionnelle khmère", *SK* 6, 1983 : 135-170.

18- "L'Industrie dans le Kampuchéa démocratique", *ER,* 89-91, 1983 : 77-110.

19- "Le processus de vietnamisation au Cambodge" [centré sur fin 1979-début 1984], *PI*, 24. Eté 1984 : 177-191.

20- "La politique alimentaire des Khmers rouges", *ER*, 99-100, 1985 : 347-365.

21- "Les savoirs naturalistes populaires dans l'Ouest cambodgien", *SK* 8-9, 1985-6 : 77-181.

22- "Vietnamised Cambodia. A silent ethnocide. *IR*, n°7, July-September 1986.

23- "Migrations et répartition de la population dans l'Ouest cambodgien communisé", *Hérodote* n°49, 1988 (2) : 114-138.

24- "Khmers Rouges : des partenaires incontournables ?", *PI*, n°47, Printemps 1990 : 425-435.

25- article sur HUN SEN dans *SEA*, n°62, Mai 1990 : 10-11

26- "Social rules and political power in Cambodia", *IR*, Janv.-Mars 1990. 22 p.

27- " Cambodia. The end of the "Politique de Cour"". *IR* 32, Jul-Sept 1992.

28- "Le phnom yong, un monument funéraire de l'Ouest cambodgien", *CASE*, 29-30, 1991 : 297-308.

## IV - កំណត់អានសៀវភៅ

1- CR de M.P Ferry, M. Gessain et R. Gessain : Ethnobotanique Tenda", *JATBA*, 1974, 3.

2- CR de Ph. N. JENNER (ed.) : M*on-Khmer Studies VI*, The University Press of Hawaï, 1977, 362 p.", ASEMI IX (1-2) : 301-303.

ជំនួយមិត្តភក្តិ, សង្គមនិងមនុស្សជម់ះ



*ម៉ារីអាឡេចស្សង់ឌ្រីនម៉ារតាំង* *បានជួបសហការី* ***ប៉ូលីនឌីផុន*** *នៅក្នុងជំរុំ ជនភៀសខ្លួនខុសច្បាប់«ខាវអ៊ីដាង»នាថ្ងៃ៧ធ្នូ១៩៧៩។នេះជាជំនួបឡើងវិញនៃវុត្ថិទូទាំង២រូបដែលធ្លាប់សហការជាមួយគ្នានៅ សារមន្ទីរជាតិប្រវត្តិសាស្ត្រធម្មជាតិក្រុងប៉ារីស។ សូមអានសៀវភៅ* Georges Condominas – Richard Pottier, *Le réfugiés originaires de l’Asie du Sud-Est, rapport au Président de la République,* Paris, La Documentation française, 1982, p. 78.

## ម្ដាយធម៌កុមារីកំព្រាខ្មែរ៖



*ម៉ារីអាឡេចស្សង់ឌ្រីនម៉ារតាំង បានរូបថតជាមួយកុមារីកូនៗធម៌នៅ សណ្ឋាគារ «ស« ភ្នំពេញ*

**ម៉ារីអាឡេចស្សង់ឌ្រីនម៉ារតាំង** បានចូលរួមក្នុងពិធីអបអរសាទរក្រោយពេលការពារនិក្ខេបបទ បណ្ឌិតរដ្ឋអក្សរសាស្ត្រនិងមនុស្សសាស្ត្រ របស់  បណ្ឌិតសភាចារ្យ ឃីងហុកឌីនៅសាកលវិទ្យាល័យស្ត្រាស្បួរបោនក្រុងប៉ារីសនាឆ្នាំ១៩៩៣។



ពីឆ្វេងទៅស្តាំ គឺ សាស្ត្រាចារ្យ ពីយ៉េរប៊ែរណាឡាហ្វុង(Pierre Bernard Lafont),
បណ្ឌិតសភាចារ្យម៉ក់ភឺន, សាស្ត្រាចារ្យព្រុយណូដាហ្សង្ស(Bruno Dagens),
បណ្ឌិតសភាចារ្យ ឃីងហុកឌី, បណ្ឌិត **ម៉ារីអាឡេចស្សង់ឌ្រីនម៉ារតាំង**

(Marie Alexandrine Martin)

## *កំណត់អានសៀវភៅ*

*Introduction à l'ethnobotanique du Cambodge.*
Paris : CNRS/CEDRASEMI, 1971. 257 p. + XX planches




*__ម៉ារីអាឡិចសង់ឌ្រីនម៉ារតាំង__ ដំបូងជាធម្មជាតិវិទូ បានសិក្សាស្រាវជ្រាវលើប្រទេសកម្ពុជានិងរុក្ខជាតិដែលខ្មែរបរិភោគ។ ការស្រាវជ្រាវនេះបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលជាតិស្រាវជ្រាវវិទ្យាសាស្ត្រ សហការជាមួយមជ្ឈមណ្ឌលឯកសារនិងស្រាវជ្រាវអាស៊ីអគ្នេយ៍ដែលដឹកនាំដោយសាស្ត្រាចារ្យកុងដូមីណាស*(G.Condominas)*។ សៀវភៅនេះទៀតសោត__ម៉ារីអាឡិចសង់ឌ្រីន__*

**ម៉ារតាំង** បានទាញចេញពីនិក្ខេបបទបណ្ឌិត ដែលកញ្ញាបណ្ឌិតបានការពារនៅសាកលវិទ្យាល័យក្រុងប៉ារីសនាឆ្នាំ១៩៦៨។ក្រោយមកកញ្ញាបណ្ឌិតបានត្រឡប់ទៅតណ្ហចិនវិញដើម្បីបន្តការស្រាវជ្រាវស្តីពី «ជីវរុក្ខជាតិសាស្ត្រ» ហើយក្នុងសៀវភៅនេះមានបង្ហាញបញ្ជីរុក្ខជាតិប្រមាណ៥០០ដែលប្រើប្រាស់ដោយប្រជាជនខ្មែរ។បញ្ជីនេះចំណារ ជាអក្សរសូរសព្ទបែបអន្តរជាតិ (transcription phonétique internationale) និង អក្សរសម្រាប់អ្នកស្រាវជ្រាវភាសាអក្សរខ្មែរ (translittération)។ សៀវភៅមានសារៈប្រយោជន៍ដល់ជីវរុក្ខជាតិវិទូ,ក្សេត្រសាស្ត្រវិទូ, ភាសាវិទូ និងប្រវត្តិវិទូ (គឺនាំឲ្យដឹងថា រុក្ខជាតិខ្លះហូរចូលកម្ពុជាពីប្រទេសណាវាងឆ្នាំណា)។

នៅទំព័រក្រោយ មាន«តារាងអក្សររៀង» (Index)នាំឲ្យងាយស្រួលក្នុងការរុករកឈ្មោះរុក្ខជាតិនិមួយៗ។

តាមការយល់របស់ប៉ាស្កាលមេដឺវីល (Pascal MEDEVILLE) ជាអ្នកឯកទេសខេមរភាសានិងភាសាចិនធ្វើការនៅកម្ពុជាបានស្រាវជ្រាវពីវិជ្ជាម្ហូបអាហារនៅភ្នំពេញបានបញ្ជាក់ថា៖ «ជំពូកទី២នៃសៀវភៅនេះបានបង្ហាញពីការស្រាវជ្រាវដោយបានធ្វើបញ្ចែកតាមប្រភេទប្រើប្រាស់គឺជារុក្ខជាតិសម្រាប់ជាអាហារ, រុក្ខជាតិសម្រាប់ទំពា, រុក្ខជាតិជាថ្នាំកែរោគ, រុក្ខជាតិផ្តល់ជាឈើប្រើប្រាស់, រុក្ខជាតិសម្រាប់តម្បាញ, រុក្ខជាតិសក្ការៈ, រុក្ខជាតិសម្រាប់សម្អ...)។ ចំណែកដែលជាទីគាប់ចិត្តសម្រាប់ខ្ញុំគឺចំណែកស្តីពី រុក្ខជាតិសម្រាប់ធ្វើជាអាហារ។សៀវភៅនេះមាន«តារាងអក្សររៀង» (Index)ដែលនាំឲ្យស្រួលក្នុងការរុករកនាមសព្ទរុក្ខជាតិនានា។ការស្រាវជ្រាវនេះមានសារៈប្រយោជន៍សំខាន់ជួយបំពេញ «វចនានុក្រម

*វុក្ខជាតិ ប្រើប្រាស់ក្នុងប្រទេសកម្ពុជា» ដោយ ប៉ូលីនឌីផុន* (Pauline DY PHON)[4] *ដែលមានកំណត់ខ្ទីពេកចំពោះខ្ញុំ។*[5]

*Le mal cambodgien. Histoire d'une société traditionnelle face à ses leaders politiques 1946-87*. Paris : Hachette (Histoire des gens), 1989. 304 p. [Traduit en anglais : *Cambodia, a shattered society*. TheUniversity of California Presse, 1994, 398 p]. Traduit en khmer, *បកប្រែជាខេមរភាសាចំណងជើងថា«ជំងឺកម្ពុជា» ដោយ ទីឃាយុ,ភ្នំពេញ, ១៩៩០, ៤១១ ទំព័រ ។*

---

[4] *«វចនានុក្រមរុក្ខជាតិ ប្រើប្រាស់ក្នុងប្រទេសកម្ពុជា» បណ្ឌិតប៉ូលីនឌីផុន, ភ្នំពេញ, ២០០០, ៩១៥ទំព័រ*

[5] *ស៊ីត* wordpress *របស់ប៉ាស្កាលមេដឺវិល* : Khmerologie.wordpress.com










*សៀវភៅ «ជំងឺកម្ពុជា ឬ ទុក្ខខ្មែរ ឬ ដួងចិត្តខ្មែរ»* **នេះ ម៉ារីអាឡេចស្សង់ឌ្រីនម៉ារតាំង** *បដិសន្ធិឡើងពីផលនៃការស្រាវជ្រាវកញ្ញាបណ្ឌិតលើកម្ពុជាជាច្រើនទសវត្សរ៍*

*នេះសេចក្ដីសង្ខេបៈ*

*១) ពីឆ្នាំ១៩៤៦ដល់១៩៥៣ប្រទេសកម្ពុជាបានរើចេញពីនឹមបារាំង។*

*កម្ពុជាបង្ហាញដល់ពិភពលោកមុខមាត់ថ្មីស្អាត សន្តិភាពនិងភាពញញឹមប្រិមប្រិយក្ដីថ្មដោយគ្មានល្អក់កករដោយសង្គ្រាមទាមទារពីអាណានិគម។ សង្គមខ្មែរបានរកឃើញរចនាសម្ពន្ធសក្តិភូមិសម័យដោយឥតមានប្រែប្រួលនាសម័យអាណាព្យាបាលបារាំង។*

*២)ក្នុងក្រុមអ្នកប្រឆាំងគឺក្រុមជំនាន់អ្នកបានទទួលការសិក្សាដែលរង់ចាំទំនើបកម្មសីលធម៌និងនយោបានប្រទេស។ចំពោះវង្វង់ប្រជាជន, គួររាវរកកន្ទង់នានាដែលបណ្ដាលឲ្យភាពរញ្ជួយទូទៅនាំឲ្យខូចខាតបន្តិចម្ដងៗទិដ្ឋភាពសង្គមនិងនយោបាយ។ឱនភាពសេដ្ឋកិច្ចដែលនាំឲ្យមានការកើតមានកោលាហលចាប់តាំងពីទសវត្សរ៍១៩៦០។នេះជាហេតុនាំឲ្យមានការបើកទ្វារចំហ ឲ្យរដ្ឋអំណាចខ្មែរក្រហមនិងការកាចសាហាវឃោរឃៅជាហេតុនាំឲ្យបាត់បង់ភូមិស្រុកដែលដូនតាបានថែរក្សាជាច្រើនសតវត្សរ៍, ចាប់ចង់កសិករ, ធ្វើចំណាប់ខ្មាំង, ជន្លាសប្រជាជន, ធ្វើបាបបុកម្នេញជាទូទៅ, សម្លាប់ពាសពេញ...ឃើញនៅវាលពិឃាតរាប់មិនទាន់អស់។ល។*

*៣)ការវិភាគលំអិតលើសង្គមខ្មែរដោយហ្មត់ចត់គ្មានសមគំនិតនឹងបញ្ញាជននយោបាយខ្មែរដើម្បីបញ្ជាំងពន្លឺពិតលើអនាគតប្រជាជន។*

*ការរុករកស្រាវជ្រាវលើឯកសារទំនើបៗ,លើបណ្ណសារនិងសក្ខីភាពផ្ទាល់បានបង្ហាញពីការបន្តនយោបាយខ្មែរតាំងពីសម័យនរោត្តមសីហនុរហូតដល់សម័យគ្រប់គ្រង់ដោយវៀតណាតតាមអន្តរកាលសម័យសាធារណៈរដ្ឋនិងសម័យខ្មែរក្រហម។ទាំងនេះបញ្ជាក់ពីច្បាប់បញ្ញត្តិសង្គតាំងពីបុរាណចារ្យសម្រាប់ឃោសនារបស់អ្នកដឹកនាំខ្មែរជាវៀងរហូតមក។*

*៤)សម្រាយចំណងពីភាពច្របូកច្របល់ខ្មែរគឺអាស្រ័យទៅលើប្រទេសជិតខាងនិងប្រទេសមហាអំណាច។ ការដោះស្រាយអន្តរជាតិគឺមិនពិតជារកបានសន្តិភាពប្រាកដឡើយ...*

*៥)**ម៉ារីអាឡេបស្សង់ឌ្រីនម៉ារតាំង** ជាជម្មជាតិវិទូ, ជាជាតិពិន្ទុវិទូ, នាយកការ*

ស្រាវជ្រាវនៅមជ្ឈមណ្ឌលស្រាវជ្រាវវិទ្យាសាស្ត្រក្រុងប៉ារីសជាយូរឆ្នាំមកហើយៗ បានរស់នៅប្រទេសកម្ពុជាអស់រយៈពេលប្រហែល១៥ឆ្នាំ។

## មាតិការឿង


- ជំពូក១៖ កម្ពុជាសន្តិភាព

- ទំព័រ.23 : សង្គមអភិរក្ស
-ទំព័រ .43 : មរតកអណានិគម
- ទំព័រ.57 : កំណើតសញ្ចេតនាជាតិនិយម
- ទំព័រ.71 : នយោបាយសម្តេចសីហនុ៖ ស្ថេរភាពផុយស្រួយ
- ទំព័រ.103 : បុព្វសញ្ញាបង្ហាញការប្រែប្រួល

- ជំពូក២៖ កម្ពុជាក្នុងការឈឺចាប់
- ទំព័រ.125 :មហន្តរាយសម័យសាធារណរដ្ឋខ្មែរ
- ទំព័រ.156 : ឃាតកម្ម សម័យខ្មែរក្រហម
- ទំព័រ.206 : កម្ពុជាវៀតណាមឧបនីយកម្ម
- ទំព័រ.228 : អនាគតបញ្ចេញពន្លឺព្រឹមៗ
- ទំព័រ..249 : អប្បរាមិនព្រមស្លាប់ៗ


សេចក្តីសង្កេត៖

សៀវភៅ «Le mal cambodgien » នេះមានការបកប្រែជាភាសាអង់គ្លេសប្រាំឆ្នាំក្រោយមកគឺនៅឆ្នាំ១៩៩២ដោយមានចំណងជើងថា« *Cambodia, a*

*shattered society »ដោយមានកែនិងបន្ថែមទិន្នន័យថ្មីទៀតខ្លះៗ[6] ហើយក៏មានការបកប្រែជាខេមរភាសាចំណងជើងថា«ជំងឺកម្ពុជា» ដោយលោក ទីឃាយុ[7] នៅឆ្នាំ១៩៩០។*

*កំណត់អានសៀវភៅ* «Le mal cambodgien *ជំងឺកម្ពុជា ឬ ទុក្ខខ្មែរ ឬ ដួងចិត្តខ្មែរ» ដោយលោកលោក* **ឧបសៅសដ្ឋា៖**

*«សៀវភៅ«ជំងឺកម្ពុជា»របស់បណ្ឌិត**ម៉ារី អាឡេចស្សង់ឌ្រីនម៉ារតាំង** នេះ លោក* **ឧបសៅសដ្ឋា** *បានធ្វើកំណត់អានចុះផ្សាយក្នុងស៊ីត«សេរីការ»លោកម្តងហើយនាឆ្នាំ២០១៨ ដូចបានស្រង់ខាងក្រោមនេះលោកបានដាក់ចំណងជើងបកប្រែថា«**ដួងចិត្តខ្មែរ**» វិញហាក់ដូច ជាពិរោះស្តាប់ជាងសម្រាប់ខ្មែរទូទៅ៖*

---

[6] *សូមអានចំណាប់អារម្មណ៍និងសង្កេតខ្លះៗដោយសាស្ត្រាចារ្យ* Hugues TERTRAIS *ឯកទេសផ្នែកនយោបាយអន្តរជាតិនៅសាកលវិទ្យាល័យក្រុងប៉ារីស៍ ទី១។ វិភាគលោកចុះផ្សាយក្នុងទស្សនាវដ្តីសាលាបារាំងចុងបូព៌ា, ភាគ៨៣, ១៩៩៦, ទំព័រ៤១៩-៤២១។*

[7] *ទីឃាយុ (នាមដើមគឺទេពម៉េងឃាន)ជាអ្នកជំនាញខាងបកប្រែសៀវភៅភាសាបារាំងមកជាខេមរភាសា ជាពីសេសលោកបានបកប្រែសៀវភៅ«ប្រវត្តិសាស្ត្រប្រទេសកម្ពុជា»ដោយអាដេម៉ារឡឺក្លែរមកជាភាសាខ្មែរបោះពុម្ពនៅភ្នំពេញឆ្នាំ២០០៥។*




# ដួងចិត្តខ្មែរ

លោកស្រី Marie Alexandre Martin[1], ស្ត្រីបារាំងសែសម្នាក់ ជាធម្មជាតិ និង ជាតិពិន្ទុវិទូ គាត់ធ្លាប់បានរស់នៅស្រុកខ្មែរ មួយរយៈកាល បានសរសេរសៀវភៅ បោះផ្សាយនៅប្រទេសបារាំង នៅឆ្នាំ ១៩៨៩ ស្ដីអំពី « អកុសលខ្មែរ »។ សៀវភៅនេះ ជាផលានៃ ដំណើរសិក្សា នៅទស្សវត្សរ៍ ៦០ នៅស្រុកខ្មែរ និង សម្ភាសន៍ នៅទស្សវត្សរ៍ ៧០ របស់លោកស្រី ជាមួយបញ្ញវន្តខ្មែរមួយចំនួន រស់នៅស្រុកបារាំង។ នៅទីនេះ យើងលើកយក ផ្នែកមួយ នៅក្នុងសៀវភៅ មានចំណងជើងថា « Khmerétude », ក្នុងនោះ លោកស្រី ដកស្រង់យក គំនិត របស់បុគ្គលមួយក្រុម មានខ្មែរ និង បរទេស ដែលលោកស្រី បានធ្វើសម្ភាសន៍ ឬ បានអាន អត្ថបទ ឬ សៀវភៅ នៃអ្នកទាំងនោះ មាន លោក សម សុខ (សម្ភាសន៍) និង ខ្មែរផ្សេងទៀត, វេជ្ជបណ្ឌិត Pannetier និង A. Pavie (សៀវភៅសរសេរនៅសម័យអាណាព្យាបាលបារាំង)។

**នេះជា ចំណារថម របស់លោកស្រី :**

សង្គមខ្មែរ ជាសង្គមនៅនឹងថ្កល់ ក្នុងរចនាសម្ព័ន្ធបូរាណ ដែលនាំឲ ចិត្តខ្មែរ គ្មានដូរសោះ តាំងពីបូរាណកាលមក : « ទន់ភ្លន់,

[1] Marie Alexandre MARTIN, naturaliste et ethnologue est directrice de recherche au CNRS. Le Mal cambodgien – Edition Hachette.

រួសរាយ, អៀនបៀន តែ លាក់ នូវការជំទាស់ និង សេចក្តីក្រៀមក្រម នៅក្នុងចិត្ត ;  មិនសូវចូលចិត្តពិភាក្សា និង ចូលចិត្ត នូវអ្វីដែលជា អំពើ បានធ្វើចប់សព្វគ្រប់ហើយ ; មាន មោទនភាពខ្លាំងក្លាណាស់ ទៅលើអតិតកាល តែមិនសូវរវល់នឹង យោបល់អ្នកដទៃ, គំនិត បើទ្វារ ដល់គំនិតទំនើប តែជា អ្នកអភិរក្សចំពោះអ្វីដែលនៅជុំវិញខ្លួន, ឆាប់ មានសេចក្តីរីករាយខ្លាំង តែមិនសូវមានអំណត់ ;  ឆ្លាត,  ចិត្តស្រាល  តែចូលចិត្ត  និយាយកំប្លែង និង ការស៊ីផឹក »(នេះជាការយល់ឃើញ របស់លោក សមសុខ)។ គំនិតបំព្រួញដ៏ប្រពៃនេះ បង្ហាញច្បាស់ នូវសក្តានុភាពនៃប្រជាជនខ្មែរ ដែលជាគុណសម្បត្តិអស្ចារ្យ របស់ខ្មែរ បើសិនខ្លួន រើសចេញ នូវទម្ងន់ នៃប្រពៃណីបាន។

ខ្មែរ  អាចរៀបរាប់  គ្មានសំរក់ទឹកភ្នែកមួយតំណក់  ដោយទឹកមុខញញឹម អំពី ភ័ព្វអាក្រក់ ពីអតិតកាល និង បច្ចុប្បន្នកាលនៃខ្លួន  ប្រកបដោយ សេចក្តីថ្លៃថ្នូរ។ នេះជាគំរូមួយ ដែលនាំអោយ ជនបរទេស ឆ្ងល់ ព្រោះ ដូចជាស្តាប់ រឿងនិទាន ដ៏សាហាវយង់ឃ្នងមួយ រៀបរាប់ផ្ទាល់ ដោយជនរងគ្រោះពិត ដោយសំនៀងផ្អែមល្ហែម។ បើប្រសិន រឿងនេះ វារៀបរាប់ដោយ ប្រជាជនផ្សេងទៀត  ច្បាស់ជាអ្នកស្តាប់  ពិបាកនឹងទ្រាំស្តាប់ណាស់។ នេះជា  គោលការណ៍ របស់ខ្មែរ  គឺ  មិនរំខានអ្នកផង  ដែលនាំអោយ គូសន្ទនា ពេញចិត្តនឹងស្តាប់។ សេចក្តីថ្លៃថ្នូរ ឋិតនៅលើផងដែរ  នូវការបង្ហាញខ្លួន  ចំពោះមុខអ្នកដទៃ  ដោយស្លៀកពាក់ត្រឹមត្រូវ និង ងូតទឹកស្អាត (ខ្មែរងូតទឹក យ៉ាងតិចបំផុត

មួយដង ឬ ពីរដងក្នុងមួយថ្ងៃ) : ខ្មែរទាំងឡាយ ជាជនស្អាត និង ចូលចិត្តតែងខ្លួន ទៅតាមមធ្យោបាយ នៃខ្លួន។ ដូចគ្នានឹង ភូមិខ្មែរ មានការរៀបចំល្អប្រពៃ និង នៅកណ្តាលទីក្រុង មានសភាពជាម្ហានរមទន ដែលទាក់ទាញ ភ្នែក និង អារម្មណ៍ អ្នកទេសចរ។ ពួកជនអឺរ៉ុប ដែលបានធ្វើការជាមួយខ្មែរ តែងតែពេញចិត្តនឹង ចរិយាល្អ របស់ដៃគូខ្លួន។ តែមាន អ្នកខ្លះ មិនយល់ថា ការស្លៀកពាក់កន្រ្តៃកកន្រ្តាក ឬ ចរិយា មិនសុភាព នៃខ្លួន ធ្វើអោយខ្មែរ ទាល់ចិត្តណាស់ ដូចគ្នានឹង ការនិយាយស្តី ជ្រុលហួស ដែលនាំអោយមាន ផលប៉ះពាល់អវិជ្ជមាន ចំពោះសេចក្តីគួរសមខ្មែរ។

ខ្មែរ ស្រឡាញ់ សេរីភាពបុគ្គល យ៉ាងស្វិតស្វាញ ហើយ សំដែង នូវកម្លាំងខ្លាំងក្លា ដើម្បីប្រឆាំងនឹងនរណា ដែលប៉ះពាល់ដល់សេរីភាពនោះ; ប៉ុន្តែខ្មែរ តែងតែសម្រុះសម្រួល ជានិច្ច ជាមួយអ្នកណា ដែលទុក លទ្ធភាព អោយខ្លួន ធ្វើសកម្មភាពដោយសេរី, អ្នកណា ចេះសំចៃដល់ ជម្រៅចិត្ត របស់ខ្លួន និង ជនបរទេសណា ដែលបង្ហាញ នូវសេចក្តីគួរសម និង អំណត់ ចំពោះខ្លួន ដូចខ្លួនមានចំពោះអ្នកនោះដែរ។ នៅចំពោះមុខ ជនបរទេស មិនស្គាល់, ខ្មែរ តែងតែ ប្រព្រឹត្តិតាមប្រពៃណី នៃខ្លួន, ហើយបើតម្រូវអោយខ្លួន ជួយទុក្ខធុរៈដល់ជននោះ គឺខ្លួនធ្វើដោយស្ម័គ្រចិត្ត។ តែទោះបីយ៉ាងណា ខ្មែរ តែងតែលាក់បាំងជិត នូវជីវិតខ្លួន ចំពោះ ជនបរទេស ហើយមិនចូលចិត្ត ជនណា ចូលជ្រៀតជ្រែកក្នុងជីវិតខ្លួន។ ដូចយ៉ាង សង់ សាលា ឬ ទីជម្រកដើម្បី

ទទួលភ្ញៀវ ដើម្បីមិនចង់អោយភ្ញៀវ ស្គាល់ក្នុងផ្ទះ របស់ខ្លួន (នេះជាការយល់ឃើញ របស់វេជ្ជបណ្ឌិត Pannetier)។ ពាក់ព័ន្ធនឹង ការងារ, លោក A. Pavie ធ្វើការកត់សម្គាល់ថា ខ្មែរ ទទួលស្គាល់តែ ឧត្តមភាព នៃជនអឺរ៉ុប តែមួយគត់ ដូច្នេះ ត្រូវជៀសវៀង ដាក់ខ្មែរនៅក្រោមបង្គាប់ នៃជនសៀម, ចិន ឬ យួន។ បើខ្មែរ គ្មានជម្រើស គឺប្រាកដ ជាខ្មែរ មិនសូវយកចិត្តទុកដាក់នឹង បញ្ហា នៃអ្នកត្រួតត្រានោះឡើយ ដែលនាំអោយ អ្នកទាំងនោះ យល់ច្រឡំថា ខ្មែរជាជន ខ្ជិលធ្វើការ។ ក្នុងការជជែកដេញថ្លៃ ជាមួយមេ ឬ ជនអឺរ៉ុប, ខ្មែរ បង្ហាញ នូវតម្លៃ របស់ខ្លួន ជាវិចារក:[2] ដ៏ប្រសប់។

ដូច្នេះ ខ្មែរ ស្រឡាញ់ពេញចិត្ត អោយគេ ចេះស្គាល់តម្លៃត្រឹមត្រូវ របស់ខ្លួន។ ការក្រអឺតក្រអោង គ្មានពិចារណា របស់អាមេរិកាំង នាំអោយទាល់ចិត្តខ្មែរណាស់។ រីឯ បារាំងសែស វិញ កាលពីសម័យអាណាព្យាបាល មិនសូវមាន ទទាស់ទទែងច្រើន ក្នុងការធ្វើសហការ ជាមួយខ្មែរ ព្រោះពួកគេ យល់ចិត្តគំនិតខ្មែរ។

ខ្មែរ, មានទ្រនង់[3], មិនព្រមទទួល នូវការឧបត្ថម ពីអ្នកដទៃដែលខ្លួនមិនបានស្នើសុំ។ ដូច្នេះ វាគ្មានប្រយោជន៍អ្វីនឹងទទូចនោះឡើយ ព្រោះ ខ្មែរ ទុកវា ជាការបំបាក់មុខខ្លួន។ក៏ប៉ុន្តែ ខ្មែរដឹងគុណ អ្នក ដែលបានជួយខ្លួន ហើយទុកគុណនោះ ជាអនន្តគុណ។ តែ អ្នកជួយ បើបានជួយហើយ តែឆ្លៀតរិះគន់ គឺនាំ

[2] Négociateur.
[3] មោទនភាព លាយនឹង ក្រអឺតក្រអោង។

ឲខ្មែរ មានកំហឹងខ្លាំង ចំពោះអ្នកជួយនោះ ហើយ ដូរចិត្តខ្លួន តែមួយយប់ ចំពោះអ្នកនោះ ជូនរហូតដល់ទៅនិយាយអាក្រក់ ឬ បង្កាច់បង្ខូច ពីអ្នកនោះ ជាការផ្តន្ទាទោស ដោយគ្មានមូលដ្ឋានត្រឹមត្រូវ បើសិនជាអ្នកនោះ រិះគន់ដល់ស្រុកខ្មែរ។ ដូច្នេះ ត្រូវជៀសវៀង និយាយអ្វី នាំទាំចិត្តខ្មែរ។

ខ្មែរ មាន គុណសម្បត្តិ ដែលអោយខ្លួន មានលទ្ធភាព អាចវិវត្តន៍ ទៅតាមសម័យទំនើប, ដូចយ៉ាង ខ្មែរ មករស់នៅស្រុកបារាំង ជាឧទាហណ៍ចំណានមួយ បង្ហាញ នូវសមត្ថភាព នៃការសម្របខ្លួននេះ : មនុស្សពេញវ័យ នៅមានអកប្បកិរិយា ដូចរស់នៅស្រុកខ្មែរ, ក្មេងជំទង់ ទម្លាប់បាន តិច ឬ ច្រើន នូវការរស់នៅថ្មី របស់ខ្លួន។ រីឯ កុមារ កុមារី វិញ មានប្រតិកម្មតាមតែ ឫសកំណើត របស់ខ្លួន : បើជាកូនកសិករ ហើយនៅតែទទួលការអប់រំ តាមប្រពៃណីខ្មែរជ្រុលពេក, វានាំអោយកូនក្មេងទាំងនោះ មានការពិបាកនឹង ធ្វើតាមការសិក្សាបារាំង, កូនក្មេងផ្សេងទៀត រស់នៅក្នុងគ្រួសារ បោះបង់ របៀបរស់នៅខ្មែរបូរាណ, កូនក្មេងនោះ វាបង្ហាញ នូវគំនិត បើកទ្វារ ស្មើនឹងមិត្តភក្តិបារាំង របស់ខ្លួន។ វាគ្រាន់តែ មាតាបិតា ជួយបន្ថែមឲគ្នា ចេះភាសាខ្មែរ និង ប្រវត្តិសាស្ត្រជាតិខ្លួន វាអាចនឹងមានប្រយោជន៍ ដល់ប្រជាជាតិខ្មែរទៅអនាគត ព្រោះ យុវជន ជាអនាគត នៃប្រជាជាតិ។

សេចក្តីសន្និដ្ឋាន របស់យើង គឺ យើង អញ្ជើញខ្មែរម្នាក់ៗ អោយយកចំណារ របស់លោកស្រី Marie Alexandre Martin ខាងលើ

នេះ ទៅពិចារណាថា តើវាពិតជា ដួងចិត្តខ្មែរ មែនឬទេ ? តើខ្មែរសព្វថ្ងៃ មានដួងចិត្តបែបណា ?

នៅឆ្នាំ ១៩៧៣ លោក ប៊ុណ្ណចន្ទ ម៉ុល, អ្នកនយោបាយខ្មែរម្នាក់នៅទស្សវត្សរ៍ ៤០-៥០, បានសរសេរសៀវភៅ អំពី ដួងចិត្តខ្មែរ មានចំណងជើងថា « ចរិតខ្មែរ »។ សេចក្តីនៅក្នុងសៀវភៅនោះគឺ បង្ហាញ នូវគុណវិបត្តិខ្មែរមួយចំនួន នៃ អ្នកនយោបាយខ្មែរជាទូទៅ ដែលជា កត្តាអវិជ្ជាមាន សំរាប់ស្រុកខ្មែរ។ សួរថា តើគុណវិបត្តិនោះ វាជាពន្លឺឆ្លុះ នៃចរិតខ្មែរ ? តើ សេចក្តីក្នុងសៀវភៅ របស់លោកស្រី Marie Alexandre Martin ដែលមានចំណងជើងថា « អកុសលខ្មែរ » អាចជាចម្លើយ ឬទេ ? យើងនឹងយកវាមកសិក្សានៅពេលក្រោយទៀត៕

*Les Khmers Daeum, "Khmers de l'Origine". Société montagnarde et exploitation de la forêt. De l'écologie à l'histoire*. Paris, PEFEO monographies n°183, 1997. 514 p.




**ម៉ារី អាឡេចសង់ឌ្រីន ម៉ារតាំង** *បានស្រាវជ្រាវលើប្រទេសយើងជិត៤០ឆ្នាំមកហើយរួចបានបោះពុម្ពផ្សាយជាសៀវភៅ និងជាអត្ថបទសិក្សានានានៅប្រទេសបារាំងនិងនៅបរទេស ជាពិសេស គឺ - Introduction à l'ethnobotanique du Cambodge*. Paris : CNRS/CEDRASEMI, 1971. 257 p. + XX planches. *និង Le mal cambodgien. Histoire d'une société traditionnelle face à ses leaders politiques 1946-87*. Paris : Hachette (Histoire des gens), 1989. 304 p. *ហើយសៀវភៅទី២មានការបកប្រែជាភាសាអង់គ្លេសមានចំណងជើងថា Cambodia, a shattered society*. The University of California Presse, 1994, 398 p. *ហើយសៀវភៅនេះទៀតសោតមានការបកប្រែជាខេមរភាសា*

ដោយលោក ទីឃាយុដោយដាក់ចំណងជើងថា «ជំងឺកម្ពុជា» ផ្សាយនៅឆ្នាំ ១៩៩០មាន៤១១ទំព័រ។ អ្នកស្រីបណ្ឌិតម៉ារតាំងមានតួនាទីជា នាយកស្រាវជ្រាវនៅមជ្ឈមណ្ឌលជាតិស្រាវជ្រាវវិទ្យាសាស្ត្រប្រទេសបារាំង (Directrice de recherche au CNRS)។ អ្នកស្រីម៉ារតាំងមានសញ្ញាប័ត្រថ្នាក់បណ្ឌិតផ្នែកជីវសាស្ត្ររុក្ខជាតិហើយនិងសញ្ញាប័ត្រថ្នាក់បណ្ឌិតរដ្ឋផ្នែកអក្សរសាស្ត្រនិងមនុស្សសាស្ត្រទៀតផង។ អាស្រ័យដោយចំណេះដឹងដ៏ខ្ពង់ខ្ពស់នេះហើយដែលបានជំរុញអ្នកបណ្ឌិតឲ្យចងក្រងស្នាដៃ ស្តីពី «**ខ្មែរដើម**»ដ៏ប្រសើរនេះពោលគឺចែងពីសង្គមនៅតំបន់ភ្នំក្រវាញនិងអាជីពកម្ម ព្រៃឈើ ហើយ ពណ៌នាពីជីវិតរស់នៅទីតាំងរហូតមកដល់ប្រវត្តិសាស្ត្រ។សៀវភៅដ៏ល្អប្រណិតនេះមានរូបថត, គំនូរ, ផែនទី, តារាងនានាហើយចាប់ផ្តើមដំបូងដោយបុព្វកថារបស់លោកសាស្ត្រាចារ្យហ្សកកុងដូមីណាស (Georges Condominas)។ បន្ទាប់មកគឺផ្តើមសេចក្តីដោយអ្នកនិពន្ធ។ ចំណែកឯអង្គសេចក្តីចែកចេញជា៧ជំពូកហើយបញ្ចប់ដោយអវសានកថា ព្រមទាំងមានឧបកម្ពន្ធ៤, បញ្ជីឯកសារគន្ថនិទ្ទេសនិងតារាងនានា។

ក្នុងអង្គសេចក្តី ៖

ជំពូកទី១គឺស្តីពីធម្មជាតិ ព្រៃ ព្រឹក្សា៖

១) ទេសភាព, ២) ថ្ម, ៣) ទឹក (រដូវ និង ប្រឡាយទឹក), ៤) ដី, ៥) ព្រៃ ដើមឈើ សត្វ (ទំព័រ១៧ដល់៥៨)។

ជំពូកទី២គឺស្តីពី៤ទសវត្សរ៍នៃប្រវត្តិសាស្ត្រ៖

១) ជាតិពន្ធុ គឺ ជនជាតិព័រ, វៀតណាម, ចិន,ថៃ, ខ្មែរ(ទំព័រ៥៩ដល់៦៤), ២)បម្លាស់លំនៅនិងព្រឹត្តិការប្រវត្តិសាស្ត្រ៖ ក) អតីតកាលនិងទៅឆ្ងាយ (ពេលប្រវត្តិសាស្ត្រនិងប្រទេសក្រៅ), ខ) ដើមកំណើត ទីតាំងមនុស្ស តាមប្រកពសំណេរនិងតាមទំនៀម សំដី, គ) ជនបរទេសដែលមកពាតត្បាតប្រជុំភ្នំ, ង)សម័យបច្ចុប្បន្ន(ទំព័រ៥៩ដល់៨២។)។

ជំពូកទី៣ គឺស្តីពីប្រជាជនព្រំប្រទល់ លំហ តំបន់ (ទំព័រ៨៣ដល់១០០) ដោយចែកជា៤ផ្នែក ហើយក្នុងផ្នែកនិមួយៗបានបំបែកជាខ្នែងតូចៗទៀត។

ជំពូកទី៤ គឺស្ដីពីផ្ទះនិងអ្នកកាន់កាប់ (ទំព័រ១០១ដល់១៤១)ដោយចែកជា៤ផ្នែក ពណ៌នាពីទិដ្ឋភាពក្រៅផ្ទះនិងក្នុងផ្ទះ, ពីការសង់ផ្ទះនិងពិធីជាប់ទាក់ទងនឹងសំណង់ផ្ទះ ពីអ្នកកាន់កាប់និងតួនាទី, ពីការមើលលើក្រុមគ្រួសារញាតិសន្តាន។

ជំពូកទី៥ គឺស្ដីពីស្រុក, ពីរដ្ឋបាល និងការប្រព្រឹត្តិក្នុងសង្គម(ទំព័រ១៤៣ដល់១៦៤) ដោយបំបែកជា៧ផ្នែកពណ៌នាពីការបែងចែកតំបន់, ទស្សនៈលើស្រុកក្នុងតំបន់ ភ្នំក្រវាញ ទំនាក់ទំនងតាមឋានានុក្រមមានបង -ប្អូន, មេ-បា, ម៉ែ-កូន, ពី ការអប់រំនិងសីលធម៌,ពីការប្រព្រឹត្តជាប់នននឹងបច្ចេកទេស សរីរៈកាយដូចជាអនាម័យ របៀបបរិភោគនិងសម្លៀកបំពាក់ អលង្ការជាដើម, ពីពុទ្ធសាសនានិងជំនឿប្រជាប្រិយ,ពីពិធីបុណ្យនានា។

ជំពូកទី៦ ស្ដីពីការដាក់ឲ្យមានគុណភាពតំបន់(ទំព័រ១៦៩ដល់២៤៤) ដោយបញ្ចែកជា២ផ្នែកធំៗមានស្រុកនិងព្រៃ។

ជំពូកទី៧ជគឺស្ដីពីទិដ្ឋភាពលើបច្ចេកទេសច្នៃប្រឌិត(ទំព័រ២៤៥ដល់២៨៦)ដោយបំបែកជា២ផ្នែកសំខាន់ៗ មានឧបភោគបរិភោគនិងសិប្បកម្ម ជំនួញដូរប្រែ។ល។ ក្នុងអវសានកថាអ្នកនិពន្ធបង្ហាញពីវិសេសភាពនិយមនៅតំបន់ភ្នំក្រវាញ(ទំព័រ២៨១ដល់២៩០)។ នៅឧបសម្ពន្ធ បានបង្ហាញពី ពិធីការនៅជនបទ, ពិធីឡើងអ្នកតាស្រុក, ពិធីសែនត្រួស, ប្រកាសបិទនៅសាលាស្រុកថ្មបាំង ដោយបន្តដូរបញ្ជីសៀវភៅនិងអត្ថបទសិក្សាយោងក្នុងស្នាដៃនេះជាសារៈសំខាន់ក្នុងការក្នុងស្រាវជ្រាវពីមនុស្សសាស្ត្រខ្មែរ។ ក្នុងតារាងអក្សរជាលំដាប់ចុងក្រោយអ្នកនិពន្ធបានឲ្យជាពិសេសនូវស្ថាននាម, នរនាម, រុក្ខនាម និងសត្វនាមតាមលំដាប់ឈ្មោះបែបខ្មែរនិងបែបវិទ្យាសាស្ត្រជាដើម។

បន្ទាប់ពីបានអានដោយយកចិត្តទុកដាក់បំផុតឃើញថាសៀវភៅនេះមានសារៈប្រយោជន៍ក្នុងការយល់ដឹងពីប្រជាជនខ្មែរយើងនៅតំបន់ភ្នំក្រវាញដែលចាត់ទុលជា«**ខ្មែរដើម**» ព្រោះបានទទួលឥទ្ធិពលយ៉ាងតិចតួចបំផុតពីបរ

*ទេស។ ស្នាដៃបណ្ឌិតម៉ារតាំងនេះជាផលចេញពីការស្រាវជ្រាវរបស់អ្នកនិពន្ធ
ជិត៤០ឆ្នាំមកហើយគឺចាប់ពីទសវត្សរ៍១៩៦០មកម្ល៉េះ។*[8]

(*កំណត់អានដោយបណ្ឌិតសភាចារ្យ* **ឃីង ហុកឌី**)

[8] *សូមអានបន្ថែមកំណត់អំណានបណ្ឌិត* Jacqueline MATRAS, « *Les Khmers Daeum, "Khmers de l'Origine". Société montagnarde et exploitation de la forêt. De l'écologie à l'histoire*. Paris, PEFEO monographies n°183, 1997. 514 p.
*Etudes rurales*, n° 199-150, 1999, Justice et sociétés rurales, pp. 239-243.